**កំណត់សម្គាល់៖**

សម្រាប់ព័ត៌មានលម្អិតនៃផលិតផល សូមយោងទៅកាន់ ខ និង លក្ខខណ្ឌនៃផលិតផលនេះ៖

**ករណីមិនធានាចំបង**

I. **ករណីដែលមិនធានា ក្នុងករណីទទួលមរណភាព ឬពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍**

ក្រុមហ៊ុន ដាយ អ៊ិឈិ ឡាយហ្វ៍ នឹងមិនទូទាត់អត្ថប្រយោជន៍ធានារ៉ាប់រងនៃបណ្ណសន្យារ៉ាប់រងនេះឡើយប្រសិនបើមរណភាពឬពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍របស់អ្នកត្រូវបានធានារ៉ាប់រង កើតឡើង ដោយសារមូលហេតុណាមួយ ទោះបីដោយផ្ទាល់ ឬដោយប្រយោលក្តី ក្នុងចំណោមហេតុការណ៍ដូចខាងក្រោម៖

ក. ធ្វើអត្តឃាតក្នុងរយៈពេល ២ (ពីរ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចាប់ផ្តើមបណ្ណសន្យារ៉ាប់រង ឬ កាលបរិច្ឆេទការចាប់ផ្តើមមានសុពលភាពនៃការបន្តសុពលភាពឡើងវិញ ដោយមិនគិតអំពីស្ថានភាពផ្លូវចិត្តរបស់អ្នកត្រូវបានធានារ៉ាប់រងដែលយកកាលបរិច្ឆេទចុងក្រោយគេ ឬ

ខ. ការប្រឈមនឹងគ្រោះថ្នាក់ដោយចេតនា ការប៉ុនប៉ងធ្វើអត្តឃាត ការប៉ុនប៉ងធ្វើបាបខ្លួនឯង ឬបង្ករបួសលើខ្លួនឯងដោយចេតនា ទោះបីស្ថិតនៅក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ ឬ

គ. ការឆ្លងមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺដែលពាក់ព័ន្ធនឹងជំងឺអេដស៍ ឬ

ឃ. ការប្រើប្រាស់គ្រឿងញៀន ឬសារធាតុញៀនខុសច្បាប់ផ្សេងទៀត ឬ

ង. បទល្មើសព្រហ្មទណ្ឌ ដែលប្រព្រឹត្តដោយម្ចាស់បណ្ណសន្យារ៉ាប់រង ឬ អ្នកត្រូវបានធានារ៉ាប់រង ឬ អ្នកទទួលផល ឬ

ច. ពិការភាព ជំងឺ ឬ របួស ដែលកើតឡើងមុនពេលកាលបរិច្ឆេទចាប់ផ្តើមបណ្ណសន្យារ៉ាប់រង ឬ កាលបរិច្ឆេទបន្តសុពលភាពឡើងវិញ

ឆ. សង្គ្រាម (ប្រកាស ឬមិនបានប្រកាស) ភាពចលាចល ឬ ប្រតិបត្តិការសង្គ្រាម សង្គ្រាមស៊ីវិល ការបះបោរ ឬ ភាពវឹកវរក្នុងប្រទេស ឬ កុប្បកម្ម ឬ កូដកម្ម ឬ ភេរវកម្ម ឬ

ជ. គ្រឿងផ្ទុះ ឬវិទ្យុសកម្មដោយសារតែអាវុធអាតូមិច នុយក្លេអ៊ែរ ឬអាវុធគីមី ឧបករណ៍ឬគ្រឿងផ្ទុះកែច្នៃ ឬ

ឈ. មរណភាព ឬការរងរបួសដែលកើតឡើងខណៈពេល ឬដោយសារតែអ្នកត្រូវបានធានារ៉ាប់រងស្ថិតក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬថ្នាំញៀន ។

ញ. ការជិះជាមួយ ឬបើកបរក្នុងការប្រណាំង កីឡាវិជ្ជាជីវៈណាមួយ ឬសកម្មភាពជ្រមុជទឹក ពាក់ព័ន្ធនឹងការប្រើប្រាស់ឧបករណ៍ដកដង្ហើម ឬ ការឡើងភ្នំ ឬការលោតឆ័ត្រយោង ឬ

ដ. សកម្មភាពហោះហើរ ឬអាកាសចរណ៍នានា លើកលែងតែការធ្វើដំណើរបង់ប្រាក់តាមយន្តហោះដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវ មានលក្ខណៈពាណិជ្ជកម្ម និងមានកាលវិភាគនៃការធ្វើដំណើរ។

II. **ករណីដែលមិនធានា សម្រាប់អត្ថប្រយោជន៍មរណភាព ឬពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍ ដែលបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ**

បន្ថែមលើចំណុចទី I ខាងលើ ក្រុមហ៊ុនដាយ អ៊ិឈិ ឡាយហ្វ៍ នឹងមិនទូទាត់អត្ថប្រយោជន៍មរណភាព ឬ ពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍ដែលបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យស្របតាមបណ្ណសន្យារ៉ាប់រងនេះឡើយ ប្រសិនបើមរណភាពឬពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍របស់អ្នកត្រូវបានធានារ៉ាប់រងកើតឡើងដោយសារគ្រោះថ្នាក់ចៃដន្យណាមួយ ទោះបីដោយផ្ទាល់ ឬដោយប្រយោលក្តីក្នុងករណី៖

ក. រាល់ការខាំ ចឹក ឬ ទិច ដោយសត្វគ្រប់ប្រភេទ រួមទាំង សត្វល្អិត មូសខាំ និង ដង្កូវ ឬ សត្វល្អិតរាតត្បាតក្នុងរាងកាយ ឬ

ខ. ខណៈពេលដែលអ្នកត្រូវបានធានារ៉ាប់រងបម្រើការជាទាហានប៉ូលីសឬអ្នកស្ម័គ្រចិត្តដែលចូលរួមក្នុងសង្គ្រាមឬការបង្ក្រាបឧក្រិដ្ឋកម្ម ឬ

គ. ខណៈពេលដែលអ្នកត្រូវបានធានារ៉ាប់រងជាអ្នកបើកយន្តហោះ ឬធ្វើការជាអ្នកបម្រើការនៅក្នុងយានហោះហើរណាមួយ ។

III. **ករណីដែលមិនធានា ក្នុងករណីជំងឺធ្ងន់ធ្ងរ**

ក. ជំងឺធ្ងន់ធ្ងរដែលត្រូវបានធ្វើរោគវិនិច្ឆ័យក្នុងរយៈពេល ៩០ ថ្ងៃដំបូងនៃកាលបរិច្ឆេទចាប់ផ្តើមបណ្ណសន្យារ៉ាប់រង ឬ កាលបរិច្ឆេទការចាប់ផ្តើមមានសុពលភាពនៃការបន្តសុពលភាពឡើងវិញដោយរាប់បញ្ចូលរាល់ជំងឺធ្ងន់ធ្ងរដំបូងទាំងអស់ដែលត្រូវបានធ្វើរោគវិនិច្ឆ័យដំបូងក្នុងអំឡុងពេលរង់ចាំ ហើយមានការវិវត្តទៅជាជំងឺធ្ងន់ធ្ងរបន្ទាប់ពីរយៈពេលរង់ចាំផុតកំណត់ ឬជំងឺធ្ងន់ធ្ងរដែលមានស្រាប់ដែលមានមុនកាលបរិច្ឆេទចាប់ផ្តើមបណ្ណសន្យារ៉ាប់រង ឬ កាលបរិច្ឆេទការចាប់ផ្តើមមានសុពលភាពនៃការបន្តសុពលភាពឡើងវិញ ។

ខ. រោគសញ្ញាកង្វះភាពស៊ាំ(ជំងឺអេដស៍)ផលវិបាកដែលកើតឡើងដោយសារជំងឺអេដស៍ឬការឆ្លងមេរោគអេដស៍;លើកលែងតែករណីនៃការឆ្លងមេរោគអេដស៍ នៅពេលបំពេញភារកិច្ចនៅកន្លែងធ្វើការជាបុគ្គលិកពេទ្យ ឬប៉ូលិស។

គ. ជំងឺធ្ងន់ធ្ងរដែលទទួលបានដោយសារផលប៉ះពាល់ពីវិទ្យុសកម្ម ឬការបង្ករោគ ដោយវិទ្យុសកម្មពីប្រភពណាមួយ។

ឃ. ជំងឺធ្ងន់ធ្ងរដែលបណ្តាលមកពីការវាយប្រហារដោយចេតនាឬដោយចៃដន្យពីភាគីណាមួយដោយប្រើអាវុធអាតូមិកជីវសាស្ត្រ និង/ឬគីមី។

ង. ជំងឺធ្ងន់ធ្ងរ ដែលកើតមានឡើងខណៈពេលដែលអ្នកត្រូវបានធានារ៉ាប់រងស្ថិតនៅក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង គ្រឿងញៀន គ្រឿងញៀនខុសច្បាប់ សារធាតុពុល ឬសារធាតុគីមីពុល។

ច. ម្ចាស់បណ្ណធានារ៉ាប់រងទទួលមរណភាពក្នុងរយៈពេល ១៤ ថ្ងៃចាប់ពីថ្ងៃដំបូងនៃការធ្វើរោគវិនិច្ឆយជំងឺធ្ងន់ធ្ងរ។

ឆ ជំងឺពីកំណើត ឬពិការភាពពីកំណើត ឬ

ជ. ការប៉ុនប៉ងធ្វើអត្តឃាត ការធ្វើបាបខ្លួនឯង ឬបង្ករបួសលើខ្លួនឯង ដោយចេតនា ទោះបីស្ថិតនៅក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ

*+សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង*
*ទៅកាន់បុគ្គលិកលក់ /ភ្នាក់ងារធានារ៉ាប់រង*

## អំពីក្រុមហ៊ុន

ដាយ អ៊ិឈិ ឡាយហ្វ៍ អ៊ីនស្សួរិនស៍ (ខេមបូឌា) ម.ក គឺជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតឈានមុខគេមួយរបស់ប្រទេសជប៉ុន ជាមួយប្រតិបត្តិការជាង១២១ឆ្នាំនៅលើសាកលលោក និងបានចុះបញ្ជីនៅក្នុងទីផ្សារភាគហ៊ុនតូក្យូស្តុកអ៊ិចឆេងនៅក្នុងឆ្នាំ២០១០។ ក្រុមហ៊ុន ដាយ អ៊ិឈិ ឡាយហ្វ៍ មានស្នាក់ការកណ្តាលនៅក្នុងទីក្រុងតូក្យូ ប្រទេសជប៉ុន និងកំពុងមានប្រតិបត្តិការអាជីវកម្មនៅក្នុងប្រទេសជាច្រើនដូចជា សហរដ្ឋអាមេរិក វៀតណាម ឥណ្ឌា ថៃ អូស្ត្រាលី ឥណ្ឌូនេស៊ី កម្ពុជា មីយ៉ាន់ម៉ា និងនូវែលសេឡង់។ ក្រុមហ៊ុន ដាយ អ៊ិឈិ ឡាយហ្វ៍ មានគ្រឹះមូលធនដ៏រឹងមាំ ជាមួយទ្រព្យសម្បត្តិសរុបចំនួន **៤៦១ ពាន់លានដុល្លារ** និងបុព្វលាភធានារ៉ាប់រងជាង **៤៩ ពាន់លានដុល្លារ** (គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣)។

ក្រុមហ៊ុន ដាយ អ៊ិឈិ ឡាយហ្វ៍ ចាប់ផ្តើមប្រតិបត្តិការអាជីវកម្មនៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ២០១៩ និងមានស្នាក់ការកណ្តាលស្ថិតនៅអាគារសាមគ្គី រាជធានីភ្នំពេញ និងសាខានៅខេត្តបាត់ដំបង និងខេត្តសៀមរាប។ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ដាយ អ៊ិឈិ ឡាយហ្វ៍ ទទួលបានពានរង្វាន់ជា "**ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតអន្តរជាតិល្អបំផុតប្រចាំឆ្នាំនៅក្នុងប្រទេសកម្ពុជា សម្រាប់ឆ្នាំ២០២៣ពីកម្មវិធីដ៏ល្បីឈ្មោះមួយ "Insurance Asia Awards 2023"** នៅក្នុងប្រទេសសិង្ហបុរី។

គិតត្រឹមខែមករា ឆ្នាំ២០២៤នេះ ក្រុមហ៊ុន ដាយ អ៊ិឈិ ឡាយហ្វ៍ បាននិងកំពុងផ្តល់ការការពារផ្នែកហិរញ្ញវត្ថុជូនប្រជាជនកម្ពុជាចំនួន **១.៨ម៉ឺនគ្រួសារ** ជាមួយទំហំទឹកប្រាក់ការពារចំនួន **១៣០លានដុល្លារអាមេរិក** និងបានទូទាត់សំណង់ជូនដល់អតិថិជនចំនួន**១៣២គ្រួសារ** ក្នុងទំហំទឹកប្រាក់ចំនួនជិត **២០ម៉ឺនដុល្លារអាមេរិក**។

ក្រុមហ៊ុន ដាយ អ៊ិឈិ ឡាយហ្វ៍ បានប្តេជ្ញាចិត្តនៅក្បែរអតិថិជនជានិច្ច និងមនុស្សជាទីស្រឡាញ់របស់ពួកគេ ដោយផ្តល់ជូននូវ "**ភាពស្ងប់ចិត្ត**" ក្រោមទស្សនៈ "**អតិថិជនជាចម្បង**"។ លោកអ្នក គឺជាអាទិភាពទី១ របស់ក្រុមហ៊ុន ដាយ អ៊ិឈិ ឡាយហ្វ៍។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង
**1800 201 202**

www.dai-ichilife.com.kh | Dai-ichi Life Cambodia | Dai-ichi Life Cambodia Official

Dai-ichi Life
នៅក្បែរអ្នកជានិច្ច

# គម្រោង EASYCare ទទួលបានទាំងការការពារ អាយុជីវិត ជម្ងឺធ្ងន់ធ្ងរ និងការសន្សំ ក្នុងគម្រោងតែមួយ

- ផ្តល់ការធានារហូតដល់ ២៥,000 ដុល្លារ (បូករួមជំងឺធ្ងន់ធ្ងរ និងប្រាក់សន្សំ)
- បង់បុព្វលាភ ធានារ៉ាប់រងរយៈពេលខ្លី ទទួលបានការការពារ រយៈពេលវែង
- មិនតម្រូវឱ្យមាន ការពិនិត្យសុខភាព



## គម្រោង EASYCare ផ្តល់ជូនអត្ថប្រយោជន៍ធំៗ ចំនួន៤ សម្រាប់លោកអ្នក និងក្រុមគ្រួសារ

១ **ការការពារហិរញ្ញវត្ថុដ៏រឹងមាំ**

ចំនួនទឹកប្រាក់នៃអត្ថប្រយោជន៍ធានារ៉ាប់រងរហូតដល់ ២៥,០០០ ដុល្លារ (រាប់បញ្ចូលទាំងអត្ថប្រយោជន៍ការពារជំងឺធ្ងន់ធ្ងរ)។ ដូច្នេះ អនាគតហិរញ្ញវត្ថុរបស់គ្រួសារអ្នកនឹងត្រូវបានការពារ មិនថាមានហេតុការណ៍មិនរំពឹងទុក ណាមួយកើតឡើង។

២ **សាច់ប្រាក់ត្រឡប់មកវិញលើសពី ១០០% នៃបុព្វលាភឆ្នាំទី ១**

នៅចុងបញ្ចប់នៃគម្រោងការការពារអ្នកនឹងទទួលបានប្រាក់ត្រឡប់មកវិញលើសពី ១០០% នៃបុព្វលាភឆ្នាំទី១។

៣ **បុព្វលាភធានារ៉ាប់រងរយៈពេល២ឆ្នាំ ការការពាររយៈពេល៦ឆ្នាំ**

លោកអ្នកធ្វើការបង់បុព្វលាភធានារ៉ាប់រងតែ២ឆ្នាំប៉ុណ្ណោះ ប៉ុន្តែនឹងទទួលបានការការពារសម្រាប់រយៈពេល៦ឆ្នាំ។

៤ **មិនតម្រូវឱ្យមានការពិនិត្យសុខភាព**

លោកអ្នកចំណាយពេលវេលាតិច ក្នុងការទិញ EASYCare ពីព្រោះមិនតម្រូវឱ្យមានការត្រួតពិនិត្យសុខភាពនោះទេ។លោកអ្នកគ្រាន់តែតម្រូវឱ្យ ឆ្លើយសំណួរមួយចំនួនតែប៉ុណ្ណោះ។



| *អត្ថប្រយោជន៍ធានារ៉ាប់រង | | |
|---|---|---|
| | **មរណភាព ឬពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍ មិនមែនបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ** | **១០០% (មួយរយភាគរយ)** នៃទឹកប្រាក់ត្រូវបានធានា |
| | **មរណភាព ឬពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍ បណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ** | **២០០% (ពីររយភាគរយ)** នៃទឹកប្រាក់ត្រូវបានធានា |
| | **អត្ថប្រយោជន៍បន្ថែមសម្រាប់ជំងឺធ្ងន់ធ្ងរដូចជា** (មហារីកដំណាក់កាលចុងក្រោយ ជំងឺគាំងបេះដូង និង ជម្ងឺដាច់សសៃឈាមខួរក្បាល) | **៥០% (ហាសិបភាគរយ)** នៃទឹកប្រាក់ត្រូវបានធានា |
| | **អត្ថប្រយោជន៍នៅថ្ងៃផុតកំណត់(ក)** | **៦០% (ហុកសិបភាគរយ)** នៃបុព្វលាភធានារ៉ាប់រងសរុប |

(ក)អត្ថប្រយោជន៍នៅថ្ងៃផុតកំណត់និងត្រូវទូទាត់នៅថ្ងៃបញ្ចប់រយៈពេលនៃបណ្ណសន្យារ៉ាប់រង ក្នុងករណីដែលមិនមានការទាមទារសំណងនៃអត្ថប្រយោជន៍មរណភាពនិងពិការភាពទាំងស្រុងនិងអចិន្ត្រៃយ៍។

### ឧទាហរណ៍៖



លោក សំណាង មានអាយុ ៣៨ ឆ្នាំ រៀបការរួច និងមានកូនស្រីម្នាក់អាយុ ១២ ឆ្នាំ។ លោកសំណាងបានធ្វើការខ្ចីប្រាក់កម្ចីពីស្ថាប័នហិរញ្ញវត្ថុមួយចំនួន $២៥០០ ដើម្បីពង្រីកមុខរបររបស់គាត់ ។ ដោយសារលោក ជាមេគ្រួសារ គាត់ព្រួយបារម្ភថា គ្រួសាររបស់គាត់អាចនឹងត្រូវទទួលបន្ទុកនៃបំណុលរបស់គាត់ ឬជួបប្រទះនឹងបញ្ហាហិរញ្ញវត្ថុ ប្រសិនបើមានហេតុការណ៍ដែលមិនអាចរំពឹងទុកណាមួយកើតឡើងចំពោះគាត់ ។ ដើម្បីទទួលបានភាពស្ងប់ចិត្ត គាត់បានជ្រើសរើសយក ផលិតផលធានារ៉ាប់រង EASYCare របស់ក្រុមហ៊ុន ដាយ អ៊ិឈិ ឡាយហ្វ៍ ដែលផ្តល់ទាំងការការពារ អត្ថប្រយោជន៍សន្សំ និងដែលមានភាពងាយស្រួល និងមានតម្លៃសមរម្យ ។

## អត្ថប្រយោជន៍ដែលលោកសំណាង និងក្រុមគ្រួសារទទួលបាន៖

**ករណីទី១** **ក្នុងករណីមានគ្រោះអកុសលកើតឡើង**

ក្នុងឆ្នាំទី៣ នៃបណ្ណសន្យារ៉ាប់រង លោកសំណាង បានកើត ជំងឺមហារីកដំណាក់កាលចុងក្រោយ ដូចនេះ លោកសំណាង ទទួលបានប្រាក់សំណង លើអត្ថប្រយោជន៍ជំងឺធ្ងន់ធ្ងរ ចំនួន ១២៥០ ដុល្លារអាមេរិក ដើម្បីជួយសម្រាលការចំណាយផ្សេងៗដែលកើតឡើង នៅពេលគ្រួសាររបស់លោកកំពុងជួបប្រទះការលំបាក។

ក្នុងឆ្នាំទី៥នៃបណ្ណសន្យារ៉ាប់រងលោកសំណាងបានទទួលមរណភាពដោយសារគ្រោះថ្នាក់ចៃដន្យដូចនេះគ្រួសាររបស់លោកសំណាងទទួលបានប្រាក់សំណងលើអត្ថប្រយោជន៍មរណភាពដោយសារគ្រោះថ្នាក់ចៃដន្យចំនួន ៥០០០ដុល្លារអាមេរិក ដើម្បីផ្គត់ផ្គង់រាល់ចំណាយផ្សេងៗ រួមទាំងការបង់ប្រាក់បំណុល បន្ទាប់ពីអវត្តមានរបស់លោក។

**ករណីទី២** **ក្នុងករណីមិនមានគ្រោះអកុសលកើតឡើង**

លោកសំណាង បាននៅជាមួយក្រុមហ៊ុន ដាយ អ៊ិឈិ ឡាយហ្វ៍ រហូតដល់កាលបរិច្ឆេទបញ្ចប់ និង មិនមានការទាមទារសំណង លើអត្ថប្រយោជន៍ទាំងអស់។ ដូចនេះលោកសំណាង ទទួលបានអត្ថប្រយោជន៍ការរស់រានមានជីវិត ចំនួន ៣៦០ដុល្លារអាមេរិក ហើយលោកសំណាងអាចយកទឹកប្រាក់ទាំងនេះ ដើម្បីជាកាដូសម្រាប់កូនស្រីរបស់គាត់សម្រាប់ការបញ្ចប់ការសិក្សាទុតិយភូមិ ។

*សូមមើលបញ្ញត្តិបណ្ណសន្យារ៉ាប់រងសម្រាប់ ខ និងលក្ខខណ្ឌពេញលេញ